# អាជ្ញាធរគ្រប់គ្រងការដឹកជញ្ជូនរបស់វ៉ាលីនៃទីក្រុងសាន់តាក្លារ៉ា (Santa Clara Valley Transportation Authority, VTA) ចំពោះជំពូក VI

## ការប្តេជ្ញាចិត្តរបស់ស្ថាប័ន

ទីក្រុងសាន់តាក្លារ៉ា ដែលជាបេះដូងនៃ Silicon Valley គឺជាទីលំនៅរបស់សហគមន៍មួយក្នុងចំណោមបណ្តាសហគមន៍ដែលមានការកែប្រែថ្មី ភាពច្នៃប្រឌិត និងភាពចម្រុះនៅក្នុងទីក្រុង។ ជាមួយនឹងប្រជាជន 1.7 លាន នាក់ ប្រជាជនរបស់ទីក្រុងជាងពាក់កណ្តាល និយាយភាសាក្រៅពីភាសាអង់គ្លេសនៅផ្ទះ ដោយប្រៀបធៀប មានចំនួនត្រឹមតែ 20% នៃប្រជាជនសហរដ្ឋនៅក្នុងប្រជាសាស្ត្រដូចគ្នានេះ។

ដោយសារតែមូលដ្ឋានអតិថិជនពហុវប្បធម៌របស់យើងខ្ញុំ VTA ទទួលស្គាល់នូវឱកាស និងកាតព្វកិច្ចរបស់ខ្លួន ដោយការធានាយ៉ាងសកម្មថា គោលការណ៍ សេវា និងកម្មវិធីរបស់យើងខ្ញុំ ត្រូវបានផ្តល់ជូនដោយឧបករណ៍ ទំនាក់ទំនង និងដំណើរការដែលមានលក្ខណៈរួមបញ្ចូលគ្នា និងមានប្រសិទ្ធិភាព។ តាមរយៈសកម្មភាព ទាំងនេះ យើងខ្ញុំអាចធ្វើឲ្យប្រាកដថា មិនមាននរណាម្នាក់ដោយសារតែជាតិសាសន៍ ពណ៌សម្បុរ ឬជនជាតិ ដើមរបស់ខ្លួន ត្រូវបានបដិសេធមិនឲ្យចូលប្រើប្រាស់សេវាដឹកជញ្ជូន កម្មវិធី និងព័ត៌មានរបស់យើងខ្ញុំឡើយ។

VTA គាំទ្រគោលបំណងរបស់ជំពូក VI និងសេចក្តីបង្គាប់ប្រតិបត្តិរបស់ជំពូកនេះស្តីពីភាពស្ទាត់ជំនាញភាសាអង់គ្លេសមានកម្រិត (Limited English Proficiency - LEP) និងយុត្តិធម៌បរិស្ថាន (Environmental Justice) ដើម្បីផ្តល់ជូនការចូលប្រើប្រាស់សេវា គម្រោង និងសកម្មភាពរបស់ខ្លួនដោយជនមានចំណូលទាប ជនជាតិភាគតិច និងជនមានភាពស្ទាត់ជំនាញភាសាអង់គ្លេសមានកម្រិត។

VTA ប្តេជ្ញាចិត្តយ៉ាងខ្លាំងក្នុងការបំពេញតាមសេចក្តីតម្រូវបទប្បញ្ញត្តិរបស់ខ្លួនស្ថិតក្រោមជំពូក VI ។ ស្ថាប័នត្រូវបានរៀបចំរចនាសម្ព័ន្ធត្រឹមត្រូវ អាស្រ័យហេតុនេះថែរក្សា និងគ្រប់គ្រងការបង្កើតគោលការណ៍ ការបណ្តុះបណ្តាល ការអនុវត្តតាមបទប្បញ្ញត្តិ ការរាយការណ៍ និងការត្រួតពិនិត្យគោលការណ៍ប្រឆាំងការរើសអើងទាំងអស់ ដោយសារខ្លួនពាក់ព័ន្ធនឹងជំពូក VI ហើយ LEP ត្រូវបានផ្តោតទៅលើផ្នែកតែមួយគឺការិយាល័យសិទ្ធិពលរដ្ឋ។ និយោជិកពីផ្នែកនីមួយៗនៅក្នុងស្ថាប័ន ធ្វើការសហការរួមចំណែកដល់ជោគជ័យរបស់កម្មវិធីជំពូក VI របស់យើងខ្ញុំ។

ពាក់ព័ន្ធនឹងជំពូក VI នេះ VTA នឹង:

- ធ្វើឲ្យប្រាកដថា កម្រិត និងគុណភាពនៃសេវាដឹកជញ្ជូន ត្រូវបានផ្តល់ជូនដោយមិនគិតពី ជាតិសាសន៍ ពណ៌សម្បុរ ឬជនជាតិដើម។
- កំណត់ និងដោះស្រាយតាមសមរម្យ ផលប៉ះពាល់បរិស្ថាន និងសុខភាពមនុស្សអវិជ្ជមាន និងមិនមានសមាមាត្រខ្ពស់ ដោយរួមទាំងផលប៉ះពាល់សង្គម និងសេដ្ឋកិច្ចនៃកម្មវិធី និង សកម្មភាព ទៅលើប្រជាជនជនជាតិភាគតិច និងប្រជាជនមានចំណូលទាប។
- ជម្រុញឲ្យមានការចូលរួមពេញលេញ និងយុត្តិធម៌អំពីប្រជាជនរងផលប៉ះពាល់ទាំងអស់ នៅក្នុងការធ្វើសេចក្តីសម្រេចអំពីការដឹកជញ្ជូន។
- ទប់ស្កាត់ការបដិសេធ ការកាត់បន្ថយ ឬការពន្យារពេលនៅក្នុងអត្ថប្រយោជន៍ពាក់ព័ន្ធ កម្មវិធី និងសកម្មភាពដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនជនជាតិភាគតិច ឬប្រជាជន មានចំណូលទាប។
- ធ្វើឲ្យប្រាកដថាចូលប្រើប្រាស់បានកម្មវិធី និងសកម្មភាពដោយជនដែលមានភាពស្ទាត់ជំនាញភាសាអង់គ្លេសមានកម្រិត។

# សេចក្តីជូនដំណឹងដល់សាធារណៈជន

អាជ្ញាធរគ្រប់គ្រងការដឹកជញ្ជូនរបស់វ៉ាលី (VTA) នៃទីក្រុងសាន់តាក្លារ៉ា សូមជូនដំណឹងជាសាធារណៈអំពីគោលការណ៍របស់ខ្លួន ដើម្បីធានាឲ្យមានការអនុវត្តទាំងស្រុងតាមជាយថល VI នៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋឆ្នាំ 1964 (Title VI of the Civil Rights Act of 1964) និងបញ្ញត្តិពាក់ព័ន្ធទាំងអស់។ ថាយថល VI ចែងថា “មិនមាននរណាម្នាក់នៅក្នុងសហរដ្ឋ ផ្អែកតាមមូលដ្ឋាននៃជាតិសាសន៍ ពណ៌សម្បុរ ឬជនជាតិដើម ត្រូវបានដកចេញពី ការចូលបដិសេធនូវអត្ថប្រយោជន៍ ឬស្ថិតក្រោមការរើសអើងក្រោមកម្មវិធី ឬសកម្មភាពណាមួយរបស់ VTA ។

ដើម្បីស្នើសុំព័ត៌មានបន្ថែមអំពីថាយថល VI របស់ VTA និងកាតព្វកិច្ចប្រឆាំងការរើសអើងផ្សេងទៀត ឬដើម្បីសាកសួរអំពីសេវាដឹកជញ្ជូន គម្រោង និងការសិក្សារបស់ VTA សូមទូរស័ព្ទមកកាន់មជ្ឈមណ្ឌលបម្រើសេវាអតិថិជនតាមរយៈលេខ (408)321-2300/(408)321-2330 លេខទូរស័ព្ទសំរាប់ជនគ ឬថ្លង់ ឬតាមរយៈអ៊ីម៉េល តាម customer.service@vta.org។ ឯកសារទាំងឡាយ អាចត្រូវបានផ្តល់ជូនជាភាសាក្រៅពីភាសាអង់គ្លេស ឬទម្រង់ដែលអាចចូលប្រើប្រាស់បានសំរាប់ជនពិការ។

នរណាម្នាក់ជឿជាក់ថា ខ្លួនត្រូវបានដកចេញពីការចូល បដិសេធនូវអត្ថប្រយោជន៍ ឬស្ថិតក្រោមការរើសអើង ក្រោមសេវា កម្មវិធី ឬសកម្មភាពណាមួយរបស់ VTA ហើយជឿជាក់ថាការរើសអើងផ្អែកលើជាតិសាសន៍ ពណ៌សម្បុរ ឬជនជាតិដើម អាចដាក់បណ្តឹងតវ៉ាផ្លូវការ។ ការការពារការប្រឆាំងការរើសអើងនេះ ក៏មានវិសាលភាព ចំពោះសកម្មភាព និងកម្មវិធីអ្នកជាប់កិច្ចសន្យាជាតតិយជនរបស់ VTA ផងដែរ។

បណ្តឹងតវ៉ាចំពោះ VTA ឬអ្នកជាប់កិច្ចសន្យាជាតតិយភាគី អាចត្រូវបានដាក់ជាលាយលក្ខណ៍អក្សរ ដោយប្រើប្រាស់ទម្រង់បែបបទបណ្តឹងតវ៉ានៃថាយថល VI (ដែលមានខាងក្រោម) ឬ ដោយការទូរស័ព្ទមកកាន់លេខ (408) 321-5571 ។ ទម្រង់បែបបទបំពេញរួច និងចុះហត្ថលេខារួច អាចត្រូវបាន ផ្ញើរទៅកាន់:

Title VI Coordinator
Office of Civil Rights
Santa Clara Valley Transportation Authority
3331 North First Street, B-1
San Jose CA 95134

ប្រសិនបើអ្នកមិនអាចដាក់បណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ បណ្តឹងតវ៉ាផ្ទាល់មាត់របស់អ្នក នឹងត្រូវបានទទួលហើយចម្លងដោយអ្នកសម្របសម្រួលនៃថាយថល VI ។ ដើម្បីធ្វើបណ្តឹងតវ៉ាផ្ទាល់មាត់ សូមទូរស័ព្ទទៅលេខ (408)321-5571 ។ បណ្តឹងតវ៉ា ត្រូវតែបានដាក់ជូនអំឡុង 180 ថ្ងៃបន្ទាប់ពីសកម្មភាពរើសអើងដែលបានចោទ ប្រកាន់ (ឬការកើតឡើងក្រោយបំផុត)។

បណ្តឹងក៏អាចត្រូវបានដាក់ដោយផ្ទាល់ជាមួយគណៈកម្មការផ្តល់ឱកាសការងារស្មើភាព (Equal Employment Opportunity Commission - EEOC) តាមរយៈ www.eeoc.gov រដ្ឋបាលផ្ទេររបស់សហព័ន្ធ (Federal Transit Administration - FTA) តាមរយៈ www.fta.dot.gov ឬក្រសួងគ្រប់គ្រងការងារ និងទីជម្រកស្មើភាព (Department of Fair Employment and Housing - DFEH) តាមរយៈ www.dfeh.ca.gov ។ សូមពិនិត្យមើលព័ត៌មាននៅលើវេបសាយរបស់ភ្នាក់ងាររៀងគ្នា សំរាប់សេចក្តីលំអិតអំពីការដាក់បណ្តឹងតវ៉ានៃថាយថល VI ។

# ដំណើរការរបស់បណ្តឹងតវ៉ា

អាជ្ញាធរគ្រប់គ្រងការដឹកជញ្ជូនរបស់វ៉ាលី (Valley Transportation Authority, VTA) នៃទីក្រុងសាន់តាក្លារ៉ា ផ្តល់ឲ្យពលរដ្ឋទាំងអស់នូវការចូលប្រើប្រាស់ស្មើគ្នាចំពោះសេវាកម្មដឹកជញ្ជូនរបស់ខ្លួនទាំងអស់។ បន្ថែមទៀត វាជាគោលបំណង របស់ VTA ថា ពលរដ្ឋគ្រប់រូបដឹងពីសិទ្ធិរបស់ខ្លួនចំពោះការចូលប្រើប្រាស់នេះ។ វេបសាយនេះ ត្រូវបានរៀបចំដើម្បីបំរើជាឧបករណ៍អប់រំសំរាប់ពលរដ្ឋទាំងឡាយ ដើម្បីឲ្យពួកគេអាចយល់ដឹងពីច្បាប់មួយក្នុងចំណោមច្បាប់ស្តីពីសិទ្ធិពលរដ្ឋ ដែលការពារអត្ថប្រយោជន៍របស់ពួកគេនៃកម្មវិធី និងសេវារបស់ VTA ជាពិសេសសដោយសារវាពាក់ព័ន្ធនឹងចាយថល VI នៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋឆ្នាំ 1964 (Title VI of the Civil Rights Act of 1964) ។

**តើចាយថល VI គឺជាអ្វី?**

ចាយថល VI គឺជាផ្នែកមួយនៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋឆ្នាំ 1964 ដែលចែងថា "មិនមាននរណាម្នាក់នៅក្នុងសហរដ្ឋ ផ្អែកតាមមូលដ្ឋាននៃជាតិសាសន៍ ពណ៌សម្បុរ ឬជនជាតិដើម ត្រូវបានដកចេញពីការចូល បដិសេធនូវ អត្ថប្រយោជន៍ ឬស្ថិតក្រោមការរើសអើងក្រោមកម្មវិធី ឬសកម្មភាពណាមួយ ដែលទទួលបានជំនួយហិរញ្ញវត្ថុរបស់ សហព័ន្ធឡើយ"។ សូមចំណាំថា ចាយថល VI មិនបង្ហាញអំពីការរើសអើងភេទឡើយ។ វាគ្រាន់គ្របដណ្តប់លើ ជាតិសាសន៍ ពណ៌សម្បុរ និងជនជាតិដើមតែប៉ុណ្ណោះ។ ច្បាប់ស្តីពីសិទ្ធិពលរដ្ឋផ្សេងទៀត ហាមប្រាប់ការរើសអើង ភេទ។

**តើនរណាខ្លះជាជនមានភាពស្ទាត់ជំនាញភាសាអង់គ្លេសមានកម្រិត?**

ជនដែលមិននិយាយភាសាអង់គ្លេសជាភាសាមូលដ្ឋានរបស់ខ្លួន និងដែលមានសមត្ថភាពមានកម្រិតក្នុងការអាន សរសេរ ឬយល់ភាសាអង់គ្លេស អាចមានភាពស្ទាត់ជំនាញភាសាអង់គ្លេសមានកម្រិត ឬ "LEP" ។ ជនទាំងនេះ អាចមានសិទ្ធិទទួលបានជំនួយភាសា ផ្អែកតាមប្រភេទសេវា អត្ថប្រយោជន៍ ឬស្ថានភាព។

ការប្រព្រឹត្តចំពោះខុសៗគ្នាផ្អែកតាមលទ្ធភាពរបស់មនុស្សក្នុងការនិយាយ អាន សរសេរ ឬយល់ភាសាអង់គ្លេស អាចជាប្រភេទនៃការរើសអើងជនជាតិដើម។

**តើខ្ញុំដាក់បណ្តឹងតវ៉ាដោយរបៀបណា?**

ប្រសិនបើអ្នកជឿជាក់ថា អ្នកបានទទួលការប្រព្រឹត្តរើសអើងដោយ VTA ផ្អែកតាមជាតិសាសន៍ ពណ៌សម្បុរ ឬជនជាតិដើមរបស់អ្នក អ្នកមានសិទ្ធិដាក់បណ្តឹងតវ៉ាជាមួយអ្នកសម្របសម្រួលនៃចាយថល VI របស់ VTA ។ បណ្តឹង ត្រូវតែបានដាក់ជូនមិនយូរជាង 180 ថ្ងៃប្រតិទិនបន្ទាប់ពីឧប្បទ្ទហេតុនៃការចោទប្រកាន់ការរើសអើង។

**វិធីសាស្ត្រនៃការដាក់បណ្តឹងតវ៉ា**

វិធីសាស្ត្រប្រសើរ គឺដាក់បណ្តឹងតវ៉ារបស់អ្នកជាលាយលក្ខណ៍អក្សរ ដោយប្រើប្រាស់ទម្រង់បែបបទបណ្តឹងតវ៉ានៃ ចាយថល VI និងផ្ញើរវាទៅកាន់:

Title VI Coordinator
Office of Civil Rights
Santa Clara Valley Transportation Authority
3331 North First Street, B1
San Jose, CA 95134

បណ្តឹងតវ៉ាផ្ទាល់មាត់ នឹងត្រូវបានទទួល ព្រមទាំងចម្លងដោយអ្នកសម្របសម្រួលនៃចាយថល VI ។ ដើម្បីធ្វើបណ្តឹងតវ៉ាផ្ទាល់មាត់ សូមទូរស័ព្ទមកកាន់លេខ (408) 321-5571 និងសួររកអ្នកសម្របសម្រួលនៃចាយថល VI ។ បណ្តឹង តវ៉ា ក៏អាចត្រូវបានដាក់ជាមួយស្ថាប័នខាងក្រៅដូចជា គណៈកម្មការផ្តល់ឱកាសការងារស្មើភាព (Equal Employment Opportunity Commission - EEOC) តាមរយៈ www.eeoc.gov រដ្ឋបាលផ្ទេររបស់សហព័ន្ធ (Federal Transit Administration - FTA) តាមរយៈ www.fta.dot.gov ឬក្រសួងគ្រប់គ្រងការងារ និងទីជម្រក ស្មើភាព (Department

of Fair Employment and Housing - DFEH) តាមរយៈ www.dfeh.ca.gov ។ សូម
ពិនិត្យព័ត៌មាននៅលើវេបសាយភ្នាក់ងាររៀងគ្នានេះ សំរាប់សេចក្តីលំអិតអំពីការដាក់បណ្តឹងតវ៉ានៃចាយចល VI ។

ប្រសិនបើបណ្តឹងតវ៉ា ត្រូវបានដាក់ជូនជាមួយ VTA និងស្ថាប័នខាងក្រៅបន្តបន្ទាប់គ្នា បណ្តឹងតវ៉ាខាងក្រៅ នឹងមានអាទិភាពលើបណ្តឹងតវ៉ារបស់ VTA ហើយនីតិវិធីនៃបណ្តឹងតវ៉ារបស់ VTA នឹងត្រូវបានព្យួរ រង់ចាំលទ្ធផលរបស់ស្ថាប័នខាងក្រៅ។

**ការស៊ើបអង្កេត**
ក្នុងអំឡុង 10 ថ្ងៃធ្វើការនៃការទទួលបានបណ្តឹងតវ៉ាផ្លូវការ អ្នកសម្របសម្រួលនៃចាយចល VI នឹងជូនដំណឹងដល់
អ្នកដាក់បណ្តឹងតវ៉ា និងចាប់ផ្តើមស៊ើបអង្កេត (បើពុំនោះទេលុះត្រាតែបណ្តឹងតវ៉ា ត្រូវបានដាក់ជាមួយនឹងស្ថាប័ន ខាងក្រៅជាមុន ឬជាបន្តបន្ទាប់)។

ការស៊ើបអង្កេត នឹងដោះស្រាយបណ្តឹងតវ៉ាចំពោះផ្នែកណាមួយរបស់ VTA ។ ការស៊ើបអង្កេត នឹងត្រូវបានធ្វើឡើង ពាក់ព័ន្ធនឹង ព្រមទាំងស្ថិតក្រោមសេចក្តីណែនាំរបស់ផ្នែកទំនាក់ទំនងនិយោជិក (Employee Relations Department) ។

ការស៊ើបអង្កេត អាចរួមមានការពិភាក្សារបស់អ្នកដាក់បណ្តឹងតវ៉ាជាមួយភាគីរងផលប៉ះពាល់ទាំងអស់ ដើម្បី កំណត់រកបញ្ហា។
អ្នកដាក់បណ្តឹងតវ៉ា អាចត្រូវបានតំណាងដោយមេធាវី ឬអ្នកតំណាងផ្សេងទៀតតាមការ ជ្រើសរើសផ្ទាល់ខ្លួន
ហើយអាចនាំយកសាក្សី និងដាក់ជូនចម្លើយសាក្សី និងភស្តុតាងក្នុងក្របខណ្ឌនៃ ការស៊ើបអង្កេត។

ការស៊ើបអង្កេត នឹងត្រូវបានធ្វើឡើង ព្រមទាំងបញ្ចប់អំឡុង 60 ថ្ងៃនៃការទទួលបាលបណ្តឹងតវ៉ាផ្លូវការ។

ផ្អែកតាមព័ត៌មានទាំងអស់ដែលបានទទួល របាយការណ៍ស៊ើបអង្កេត នឹងត្រូវបានសរសេរដោយអ្នកសម្របសម្រួល
នៃចាយចល VI សំរាប់ការដាក់ជូនប្រធានរដ្ឋបាល (Chief Administrative Officer) ។

អ្នកដាក់បណ្តឹងតវ៉ា នឹងទទួលបានលិខិតមួយដែលបង្ហាញថា នឹងមានសេចក្តីសម្រេចចុងក្រោយយ៉ាងយូរត្រឹមចុង ថ្ងៃទី 60
នៃពេលវេលាកំណត់។ ការស៊ើបអង្កេតភាគច្រើនបំផុត ត្រូវបានបំពេញក្នុងរយៈពេល 30 ថ្ងៃ។

អ្នកដាក់បណ្តឹងតវ៉ា នឹងត្រូវបានជូនដំណឹងអំពីសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនចំពោះសេចក្តីសម្រេច។ បណ្តឹង ឧទ្ធរណ៍
អាចត្រូវបានធ្វើឡើងទៅកាន់ រដ្ឋបាលផ្ទេររបស់សហព័ន្ធ (Federal Transit Administration)
គណៈកម្មការផ្តល់ឱកាសការងារស្មើភាព (Equal Employment Opportunity Commission)
ឬក្រសួងគ្រប់គ្រងការងារ និងទីជម្រកស្មើភាព (Department of Fair Employment and Housing) ។

SANTA CLARA
Valley Transportation Authority

# ទម្រង់បែបបទបណ្ដឹងតវ៉ានៃថាយថល VI

អាជ្ញាធរគ្រប់គ្រងការដឹកជញ្ជូនរបស់វ៉ាលី (VTA) នៃទីក្រុងសាន់តាក្លារ៉ា
ការិយាល័យសិទ្ធិពលរដ្ឋ

VTA ប្ដេជ្ញាចំពោះការធានាថា មិនមានជនណាម្នាក់ត្រូវបានដកចេញពីការចូលរួមនៅក្នុង ឬត្រូវបានបដិសេធពីបណ្ដាអត្ថប្រយោជន៍នៃសេវាកម្មរបស់ខ្លួន ផ្អែកលើមូលដ្ឋាននៃជាតិសាសន៍ ពណ៌សម្បុរ ឬជនជាតិដើម ដូចដែលបានចែងដោយថាយថល VI នៃច្បាប់ស្ដីពីសិទ្ធិពលរដ្ឋឆ្នាំ 1964 ដែលត្រូវបានធ្វើវិសោធនកម្ម។ បណ្ដឹងតវ៉ានៃ ថាយថល VI ត្រូវតែបានដាក់ជូននៅក្នុងរយៈពេល 180 ថ្ងៃចាប់តាំងពីកាលបរិច្ឆេទនៃការចោទប្រកាន់ ការរើសអើង។

ព័ត៌មានខាងក្រោមមានភាពចាំបាច់ ដើម្បីជួយយើងខ្ញុំនៅក្នុងការដំណើរការបណ្ដឹងតវ៉ារបស់អ្នក។ បើសិនជាអ្នក តម្រូវឲ្យមានជំនួយណាមួយនៅក្នុងការបំពេញទម្រង់បែបបទនេះ សូមទំនាក់ទំនងអ្នកសម្របសម្រួលនៃថាយថល VI តាមរយៈការហៅទូរស័ព្ទលេខ (408) 321-5571។ ទម្រង់បែបបទដែលបានបំពេញរួចរាល់ ត្រូវតែបញ្ជូនត្រឡប់ទៅកាន់អ្នកសម្របសម្រួលនៃថាយថល VI នៃការិយាល័យសិទ្ធិពលរដ្ឋរបស់ VTA តាមអាសយដ្ឋាន 3331 North First Street, Building B-1, San Jose, CA 95134។

| | |
|---|---|
| ឈ្មោះរបស់អ្នក៖ | ទូរស័ព្ទ៖ |
| អាសយដ្ឋាន៖ | ទូរស័ព្ទផ្សេងទៀត៖ |
| | ទីក្រុង រដ្ឋ និងកូដតំបន់៖ |
| ជនដែលបានរើសអើងចំពោះ (ប្រសិនបើជនណាផ្សេងក្រៅពីអ្នកប្ដឹង)៖<br>ឈ្មោះ៖ | |
| អាសយដ្ឋាន ទីក្រុង រដ្ឋ លេខហ្សីបកូដ៖ | |

តើចំណុចណានៃបណ្ដាចំណុចខាងក្រោម ដែលពណ៌នាល្អបំផុត ចំពោះការចោទប្រកាន់នៃការរើសអើង?
(សូមគូសរង្វង់ទាំងអស់ដែលត្រូវ)

- ជនជាតិ
- ពណ៌សម្បុរ
- ជនជាតិដើម (ភាពស្ទាត់ជំនាញភាសាអង់គ្លេសមានកម្រិត)

កាលបរិច្ឆេទនៃឧប្បទ្ទហេតុ៖ ____________________

សូមរៀបរាប់ពីឧប្បទ្ទហេតុនៃការចោទប្រកាន់ការរើសអើង។ សូមផ្ដល់ឈ្មោះ និងតួនាទីរបស់និយោជិក VTA ទាំងអស់ដែលពាក់ព័ន្ធ ប្រសិនបើអាចមាន។ សូមពន្យល់ពីអ្វីដែលបានកើតមាន និងមនុស្សដែលអ្នកជឿជាក់ថាមានការទទួលខុសត្រូវ។ សូមប្រើប្រាស់ផ្នែកខាងក្រោយនៃទម្រង់បែបបទនេះ ប្រសិនបើត្រូវការកន្លែងបន្ថែម ទៀត។

________________________________________

________________________________________

## ទម្រង់បែបបទបណ្តឹងតវ៉ានៃជំពូក VI
ការដឹកជញ្ជូនរបស់វ៉ាលីនៃទីក្រុងសាន់តាក្លារ៉ា
ការិយាល័យសិទ្ធិពលរដ្ឋ

សូមរៀបរាប់ពីឧប្បត្តិហេតុនៃការចោទប្រកាន់ការរើសអើង (បន្ត) ________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________

តើអ្នកបានដាក់បណ្តឹងតវ៉ាជាមួយភ្នាក់ងារសហព័ន្ធ រដ្ឋ ឬតំបន់ណាមួយផ្សេងទៀតដែរឬទេ? (សូមគូសរង្វង់មួយ)
បាទ-ចាស/ទេ ប្រសិនបើបាទ-ចាស សូមរាយបញ្ជីភ្នាក់ងារមួយ/ច្រើន និងព័ត៌មានទំនាក់ទំនងខាងក្រោម៖

ភ្នាក់ងារ៖ ឈ្មោះទំនាក់ទំនង៖
អាសយដ្ឋាន ទីក្រុង រដ្ឋ លេខហ្សីបកូដ៖ ទូរស័ព្ទ៖

ភ្នាក់ងារ៖ ឈ្មោះទំនាក់ទំនង៖

អាសយដ្ឋាន ទីក្រុង រដ្ឋ លេខហ្សីបកូដ៖ ទូរស័ព្ទ៖

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានអានសេចក្តីចោទប្រកាន់ខាងលើ និងថាវាជាការពិតតាមចំណេះដឹង ព័ត៌មាន និងការជឿជាក់ ប្រសើរបំផុតរបស់ខ្ញុំ។

________________________________________________________________
ហត្ថលេខារបស់អ្នកប្តឹង៖ កាលបរិច្ឆេទ៖
________________________________________________________________
បោះពុម្ព ឬវាយឈ្មោះរបស់អ្នកប្តឹង

VTA Office Use Only:

Date Received: ____________________________

Received By: ______________________________

# បញ្ជីទំនាក់ទំនងសំរាប់ការចុះដល់សហគមន៍ និងថាយថល VI/LEP

ដើម្បីឲ្យសមស្របជាមួយថាយថល VI នៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋឆ្នាំ 1964 (Title VI of the Civil Rights Act of 1964) VTA ផ្តល់ឲ្យបុគ្គលទាំងអស់នូវការចូលប្រើប្រាស់ដោយមិនរើសអើង និងស្មើភាពចំពោះបណ្តាសេវាកម្មដឹកជញ្ជូន និងព័ត៌មានទាំងអស់។ VTA រក្សាទុកបញ្ជីផ្ញើរសំបុត្រ ដែលត្រូវបានប្រើប្រាស់ដើម្បីជូនដំណឹងបណ្តាស្ថាប័នដែលផ្តល់សេវាដល់ជនពិការ ជនជាតិភាគតិច អ្នកមានចំណូលទាប ឬអ្នកភាពស្ទាត់ជំនាញភាសាអង់គ្លេសមានកម្រិត អំពី កម្មវិធី ឬការផ្លាស់ប្តូរដែលបានស្នើសុំ ចំពោះសេវាដឹកជញ្ជូន។ VTA លើកទឹកចិត្តបណ្តាស្ថាប័ន ឬបុគ្គលនានាឲ្យស្ម័គ្រចិត្តបញ្ចូលព័ត៌មានទំនាក់ទំនងរបស់ខ្លួននៅលើ បញ្ជីផ្ញើរសំបុត្រ។
សូមបំពេញទម្រង់បែបបទតាមអ៊ីនធ័រណិត(http://apps.vta.org/title6/) ជា ភាសាអង់គ្លេស
ដើម្បីត្រូវបានដាក់ចូលនៅក្នុងបញ្ជីផ្ញើរសំបុត្រ។ ប្រសិនបើ អ្នកមានចម្ងល់ណាមួយ សូម ទំនាក់ទំនងមកកាន់ VTA តាមលេខទូរស័ព្ទ (408)321-2300, (408)321-2330 TTY ឬតាមរយៈអ៊ីម៉ែលតាម អាសយដ្ឋាន customer.service@vta.org.